# <u>កិច្ចការបញ្ចប់មេរៀនទី៤៦-សុជីវធម៌តាមទីសាធារណៈ ដល់ មេរៀនទី៤៧</u>

## <u>មូសិកទន្ត ឬធ្មេញកណ្ដុរ " ៉ "</u>

**អំណាន:** ចូរអានអត្ថបទខាងក្រោម រួចឆ្លើយនឹងសំណួរ ។

| | | |
|---|---|---|
| | ចម្រៀង លំនាំបទ កន្ទុបម៉ែមួយ | |
| ឱ! មិត្តអឺងអឺយប្រុសស្រី | ត្រូវចេះគួរសមរាក់ទាក់ | (ពីរដង) |
| មិនត្រូវដើរឱ្យពារប៉ះ | ឬក៏ជម្ពះស្ត្រីមានផ្ទៃពោះ ។ | (ពីរដង) |
| ពេលមិត្តឃើញចាស់ជរា | គ្រាំគ្រាតូចធំទាបខ្ពស់ | (ពីរដង) |
| មិនគួរមិនសមធ្វើសោះ | ប៉ះពាល់កិត្តយសនាំឱ្យថ្នាំងថ្នាក់។ | (ពីរដង) |
| កុមារាកុមារី | ឃ្នាតខ្សីរួសរាយរាក់ទាក់ | (ពីរដង) |
| ទើបក្លាយជាពលរដ្ឋម្នាក់ | មានសុជីវិធម៌ជាក់ក្នុងសង្គមខ្មែរ។ | (ពីរដង) |

គូសសញ្ញា ✓ ក្នុងប្រអប់ ☐ ចម្លើយមួយដែលត្រឹមត្រូវ ។

១. តើអត្ថបទនេះនិយាយពីអ្វី ?

☐ក. ការគួរសមរាក់ទាក់ ☐ខ. ការធ្វើដំណើរទីសាធារណៈ

☐គ. សុជីវធម៌តាមទីសាធារណៈ ☐ឃ. ការចេះជួយគ្នា

២. តើកុមារត្រូវមានទម្លាប់ល្អដូចម្ដេចពេលជួបមនុស្សចាស់ ?

☐ក. សម្លឹងមុខ ☐ខ. ចាប់ដៃ

☐គ. លើកដៃសំពះ ☐ឃ. ធ្វើមិនឃើញ

៣. តើពេលប្អូនដើរជិតស្ត្រីមានផ្ទៃពោះ គួរធ្វើដូចម្ដេច ?

☐ក. ដើរប្រជ្រៀត ☐ខ. រុញចេញដើម្បីទៅមុន

☐គ. ដើរប៉ះ ឬបុក ☐ឃ. មិនដើរប្រជ្រៀត ឬទង្គិច

៤. ពេលប្អូនឃើញចាស់ជរា ឬជនមានពិការភាព តើត្រូវធ្វើដូចម្ដេច ?

☐ក. ស្អប់ ខ្ពើម មិននិយាយជាមួយ ☐ ខ. មិនចង់នៅក្បែរ

☐គ. គួរសម និងយកអាសា ☐ឃ. ពេបជ្រាយ

LIVEWORKSHEETS

៥. តើដើម្បីក្លាយជាពលរដ្ឋមានសុជីវធម៌ក្នុងសង្គម តើប្អូនគួរធ្វើដូចម្ដេច ?

☐ ក. រួសរាយរាក់ទាក់ គួរសម យកអាសា    ☐ ខ. ខិតខំរៀនសូត្រ

☐ គ. ខិតខំធ្វើការងារ    ☐ ឃ. មិនផឹកស្រា លេងល្បែង

៦. ចូររកបដិសព្ទនឹងពាក្យ " មាំមួន " ។

☐ ក. ខ្សោយ    ☐ ខ. ខ្លាំង

☐ គ. រឹងប៉ឹង    ☐ ឃ. ទ្រុឌទ្រោម

៧. ចូររកវេវចនសព្ទនឹងពាក្យ " និមន្ត " ។

☐ ក. គង់    ☐ ខ. សឹក

☐ គ. យាង    ☐ ឃ. សិង

៨. ចូរជ្រើសរើសអក្សរតំណាងរូបភាពទៅបំពេញក្នុងប្រអប់ពីមុខឃ្លាះឱ្យបានត្រឹមត្រូវ ។

ក



ខ



គ



☐ ១. ខ្ញុំសូមជម្រាបសួរលោកតា ។

☐ ២. ខ្ញុំសូមជម្រាបសួរលោកយាយ ។

☐ ៣. សួស្ដី! មិត្ត តើឯងតែងតែមកអានសៀវភៅនៅទីនេះឬ ?

➢ សំណេរ

១. តើគេប្រើសញ្ញាមូសិកទន្ត ឬធ្មេញកណ្ដុរ " ៉ " សម្រាប់ធ្វើអ្វី?

➢ ..............................................................................................................

..............................................................................................................

២. តើសញ្ញាមូសិកទន្ត ឬធ្មេញកណ្ដុរ " ៉ " ប្ដូរជាបុកជើង " ុ " វិញនៅពេលណា ?

➢ ..............................................................................................................

..............................................................................................................

LIVEWORKSHEETS

៣. ចូរស្រង់ពាក្យដែលមានមូសិកទន្ត ឬធ្មេញកណ្ដុរ " ៉ " ក្នុងអត្ថបទខាងក្រោម ។

| |
|---|
| ម៉ុកអង្គុយផ្ញុំប៉ិ ក្រោយដើមចម្បាំ នៅលើកោះរ៉ុង។ រសៀលម៉ោងបី ខ្យល់ បក់ប៉ិៗ ប៉ើងសក់មីងយ៉ាំដែលកំពុងលក់ម៉ាំល្ហុងក្នុងភូមិកោះរ៉ុង។ អ្នកភូមិនាំគ្នាទិញរញ៉ឹករញ៉ិ ព្រោះគាត់ប៉ិនកំប៉ប្លែងក្រមិចក្រមើម និងចេះធ្វើឫកម៉ិកម៉ូក់ ទាក់ចិត្តអ្នកទិញឱ្យសប្បាយ។ តាង៉ែតដឹកដៃយាយយ៉ាត ដើរង៉ុកៗទៅទិញនំប៉ាវផ្ញើចៅវ៉ែនឈឺរ៉ាំរ៉ៃដេកចាំនៅផ្ទះ ។ |

.......................................................................................................................................

.......................................................................................................................................

៤. ចូរជ្រើសរើសពាក្យក្នុងប្រអប់ យកទៅបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ។

| | | |
|---|---|---|
| សុជីវធម៌ | គោរព | ទង្គិច |

១. កូនល្អត្រូវចេះ..........................................ចាស់ទុំ ។

២. ពលរដ្ឋល្អត្រូវមាន...................................ក្នុងការរស់នៅ ។

៣. ពេលយើងដើរជួបមនុស្សចាស់ ឬស្ត្រីមានផ្ទៃពោះយើងមិនត្រូវដើរ................គាត់ឡើយ ។

LIVEWORKSHEETS